ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ
រៀបចំបុណ្យជាតិ-អន្តរជាតិ
លេខៈ...១៧/...........គ.ជ.ប.អ.
/២០២៥

# ផែនការណែនាំ
## ស្តីពី
## ការរៀបចំខួបអនុស្សាវរីយ៍លើកទី ៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥

**យោង**:- ព្រះរាជក្រឹត្យលេខ នស/រកត ០៩២៤/១២០៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការបង្កើត គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

- អនុក្រឹត្យលេខ ២០៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីប្រតិទិនឈប់សម្រាក ការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០២៥
- សារាចរណែនាំ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ លេខ០៩សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ

ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៧២ នៃទិវាបុណ្យឯករាជ្យជាតិ និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី៩-១០ និងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីសម្តែងនូវទឹកចិត្តសោមនស្សរីករាយអបអរសោទរយ៉ាងភ្លៀវភ្លាបំផុត ចំពោះទិវាជាប្រវត្តិសាស្ត្រ ដែលកម្លាំងមហាសាមគ្គីជាតិទាំងមូល ដណ្តើមបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំង នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នូវឯករាជ្យជាតិដ៏ពេញបរិបូរណ៍ ក្រោមព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជាតិដ៏ឧត្តុង្គឧត្តម នៃ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"**។

ដើម្បីរៀបចំពិធីបុណ្យឱ្យប្រព្រឹត្តទៅយ៉ាងមហោឡារិក ស័ក្តិសមទៅនឹងអត្ថន័យដ៏ជ្រាលជ្រៅខាងលើ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចតទៅ ៖

*** គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រដ្ឋបាលរាជធានីភ្នំពេញ**

-សហការរៀបចំមីទ្ទិញមហាជន រម្លឹកខួបអនុស្សាវរីយ៍លើកទី ៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥ ដោយមានព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**



វិថីឧកញ៉ា ឈុន កែងវិថីព្រះស៊ីសុវត្ថិ ទល់មុខសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ E-mail: nconif@gmail.com Phone: 012 912 265 / 097 97 69 111

**នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងមានព្រះរាជវត្តមាន ព្រះវត្តមានសម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង សម្តេចព្រះសង្ឃ វត្តមានថ្នាក់ដឹកនាំកំពូលជាតិ អង្គទូត ភ្ញៀវអន្តរជាតិ ថ្នាក់ដឹកនាំ មន្ត្រីរាជការតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រដ្ឋបាលរាជធានីភ្នំពេញ និងផែនកងយោធពលខេមរភូមិន្ទ ផែននគរបាលជាតិ ផែនយុវជនកាយរឹទ្ធិជាតិកម្ពុជា ផែនយុវជនកាកបាទក្រហមកម្ពុជា ផែនសហភាពសហព័ន្ធយុវជនកម្ពុជា ផែនសម្ព័ន្ធយុវជនស្រឡាញ់សន្តិភាព លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ចូលរួមតាមចំនួន ដែលគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិបានកំណត់ ដោយផែននីមួយៗ ត្រូវកាន់បដាពាក្យស្លោក ប៉ង់កាតព្រះបរមឆាយាល័ក្ខណ៍ ទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ផ្កាចម្រុះពណ៌លើកគ្រវី ថ្វាយព្រះរាជដំណើរយាងរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ។ ឱកាសនោះក៏មានពិធីបង្ហោះប៉េងប៉ោង និងលែងព្រាប ដែលជានិមិត្តរូប នៃសុខសន្តិភាព សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងមានការអុជកាំជ្រួចអបអរសាទរ នៅយប់ថ្ងៃទី៩ និងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥។ ចំណែកនៅតាមមហាវិថីនានា មានដំឡើងផ្ទាំងប៉ាណូព្រះបរមឆាយាល័ក្ខណ៍ និងមានតុបតែងលម្អដោយទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ព្រមទាំងបដាពាក្យស្លោក ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥។

-នៅតាមដងមហាវិថីសម្តេចសុធារស និងមហាវិថីព្រះសុរាម្រឹត ពីព្រះបរមរាជវាំង ដល់វិមានឯករាជ្យ មានចាត់កម្លាំងលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ដោយមានកាន់ប៉ង់កាតព្រះបរមឆាយាល័ក្ខណ៍ ទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ និងផ្កាចម្រុះពណ៌លើកគ្រវី អបអរសាទរថ្វាយព្រះរាជដំណើររបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ។

*** ក្រសួងព្រះបរមរាជវាំង**

ណែនាំដល់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការរៀបចំខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥។

*** គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

-ណែនាំ និងសហការជាមួយរដ្ឋបាលរាជធានីភ្នំពេញ រៀបរយផែននីមួយៗ ក្នុងពិធីមីទ្ទិញនៅបរិវេណវិមានឯករាជ្យ និងតាមដងមហាវិថីសម្តេចសុធារស និងមហាវិថីព្រះសុរាម្រឹត ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

-រៀបចំកម្មវិធីជូនគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញ អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** នៅមណ្ឌបសួនច្បារខាងកើតវិមានឯករាជ្យ នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥។

*** គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញ**

-រៀបចំគណៈប្រតិភូ តាមចំនួនដែលគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ បានកំណត់ ដើម្បីអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥។

-ថ្នាក់ដឹកនាំ មន្ត្រីរាជការ ចូលរួមប្រារព្ធពិធីបុណ្យនៅវិមានឯករាជ្យ តាមចំនួនដែលគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិបានកំណត់។

-រៀបចំតុបតែងលម្អដោយបំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក តាមអង្គភាព តាមមហាវិថីនានា និងទីសាធារណៈ ក្នុងរាជធានីភ្នំពេញ ដើម្បីអបអរពិធីបុណ្យដ៏ឧត្តុង្គឧត្តមនេះ។

*** ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ**

ណែនាំអង្គភាពក្រោមឱវាទ សហការការពាររក្សាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ តាមសមត្ថកិច្ចជំនាញរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព សេចក្តីសុខក្សេមក្សាន្តជូនប្រជារាស្ត្រយើង។

*** ក្រសួងការពារជាតិ**

ត្រូវរៀបចំកម្មវិធីដោយឡែក ក្នុងការប្រារព្ធខួបលើកទី ៧២ ទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីតាំងសមស្របណាមួយ។

ចាត់កម្លាំងកងយោធពលខេមរភូមិន្ទ ចូលរួមតាមផែន នៅវិមានឯករាជ្យ ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ ព្រមទាំងរៀបចំការអុជកាំជ្រួចរយៈពេល២ថ្ងៃ គឺថ្ងៃទី៩ និងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ វេលាម៉ោង១៩:០០នាទីយប់ នៅមុខព្រះបរមរាជវាំង។

*** ក្រសួងមហាផ្ទៃ**

ចាត់កម្លាំងនគរបាលជាតិ ចូលរួមតាមផែន នៅវិមានឯករាជ្យ ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ។

*** ក្រសួងព័ត៌មាន**

-រៀបចំកម្មវិធីផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវរាល់ខ្លឹមសារ នៃទិវាបុណ្យឯករាជ្យជាតិ និងខួបកំណើតកងយោធពលខេមរភូមិន្ទ តាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ស្តីពីព្រះរាជសកម្មភាពនៃ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** កាលព្រះអង្គមានព្រះជន្មគង់នៅ និងការអភិវឌ្ឍលើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

-រៀបចំកម្មវិធីថតផ្សាយផ្ទាល់នូវព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ នៅវិមានឯករាជ្យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ បំផុត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។

*** ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

ធ្វើការណែនាំដល់គ្រប់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ រាជធានី ខេត្ត ចាត់តាំងក្រុមសិល្បៈ និងក្រុមតន្ត្រីសម័យ បុរាណ សម្តែង និងប្រគំជូនប្រជារាស្ត្រទស្សនាកម្សាន្ត តាមទីសាធារណៈ ដែលបានកំណត់។

* **ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ជួយបង្កលក្ខណៈងាយស្រួលដោះស្រាយសម្ភារៈ ថវិកា សម្រាប់បម្រើការរៀបចំពិធីបុណ្យខាងលើ ឱ្យបានសមស្រប និងទាន់ពេលវេលា។

* **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

អញ្ជើញឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត អង្គការអន្តរជាតិ ចូលរួមពិធីមីទ្ទិញនៅវិមានឯករាជ្យ ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ។

* **ក្រសួងសុខាភិបាល**

ចាត់ក្រុមវេជ្ជបណ្ឌិត មានឱសថគ្រប់គ្រាន់ និងរថយន្តគិលានសង្គ្រោះ ឱ្យប្រចាំការនៅវិមានឯករាជ្យ មណ្ឌបព្រះបរមរូប **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** ក្នុងពេលដែលគណៈប្រតិភូ អញ្ជើញដាក់កម្រងផ្កានៅវិមានឯករាជ្យ ថ្វាយកម្រងផ្កា **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** និងតាមផែននីមួយៗដែលចូលរួមមីទ្ទិញនៅវិមានឯករាជ្យ ព្រមទាំងកម្លាំងសិស្សានុសិស្ស នៅតាមមហាវិថីសម្តេចសុធារស និងមហាវិថីព្រះសុរាម្រឹត។

* **ក្រសួងរ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា**

ផ្តល់ និងរក្សាចរន្តអគ្គិសនីឱ្យបានស្ថិរភាពគ្រប់ទីកន្លែង ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ។

* **រដ្ឋបាលរាជធានីភ្នំពេញ**

-សហការជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រៀបចំមីទ្ទិញមហាជន នៅវិមានឯករាជ្យ ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ។

-ចាត់កម្លាំងមន្ត្រីរាជការ យុវជនកាយរឹទ្ធិជាតិកម្ពុជា យុវជនកាកបាទក្រហមកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ចូលរួមក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងព្រះរាជពិធីពន្លត់ភ្លើងជ័យ នៅវិមានឯករាជ្យ និងចាត់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ឈរតាមមហាវិថីសម្តេចសុធារស និងមហាវិថីព្រះសុរាម្រឹត ថ្វាយព្រះរាជដំណើរយាងរបស់ **ព្រះមហាក្សត្រ**។

-សម្អាតវិមានឯករាជ្យ បរិវេណជុំវិញវិមានឯករាជ្យ និងមណ្ឌបព្រះបរមរូប **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** បរិវេណខាងមុខព្រះបរមរាជវាំង និងតាមមហាវិថីសំខាន់ៗ ត្រូវលាបលនចិញ្ចើមថ្នល់ ទ្រូងថ្នល់ បាញ់ទឹកលាងថ្នល់ពីវិមានឯករាជ្យ ដល់ខាងមុខព្រះបរមរាជវាំង បញ្ឆាំងភ្លើងនៅវិមានឯករាជ្យ និងបំភ្លឺភ្លើង បើកទឹកលម្អតាមសួនច្បារសាធារណៈ។

-ណែនាំដល់គ្រប់មន្ទីរ អង្គភាព ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានសាធារណៈ សាលារៀន វត្តអារាម ឱ្យតុបតែងលម្អលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងបំផុសប្រជារាស្ត្រឱ្យលើកទង់ជាតិគ្រប់គេហដ្ឋាន ដើម្បីអបអរសាទរពិធីបុណ្យឯករាជ្យជាតិ ដ៏ឧត្តុង្គឧត្តម។

* **គ្រប់ខេត្ត**

-រដ្ឋបាលខេត្តនីមួយៗ ត្រូវរៀបចំពិធីមីទ្ទិញមហាជន និងពិធីគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យខេត្ត ឬទីតាំងសមស្របណាមួយ ដែលខេត្តបានកំណត់។

-ណែនាំដល់គ្រប់មន្ទីរ អង្គភាព ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានសាធារណៈ សាលារៀន វត្តអារាម ឱ្យតុបតែងលម្អលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងបំផុសប្រជារាស្ត្រ ឱ្យលើកទង់ជាតិគ្រប់គេហដ្ឋាន ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត នឹងអនុវត្តតាមស្មារតីនៃផែនការណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥

**គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

**ប្រធាន**

**សម្តេចមហាមន្ត្រី គុយ សុផល**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

## សម្រាប់ប្រើក្នុងការរៀបចំខួបអនុស្សាវរីយ៍លើកទី ៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៥

១- ចងចាំជានិច្ចនូវព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជាតិដ៏ឧត្តុង្គឧត្តម នៃ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"**

២- សូមថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** សូមបានយាងទៅសោយព្រះបរមសុខ ក្នុងសុគតិភព

៣- ជយោ! **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា

៤- សូមថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា សូមមានព្រះរាជសុខភាពល្អបរិបូរណ៍ និងព្រះជន្មាយុយឺនយូរ

៥- សូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមមានព្រះរាជសុខភាពល្អបរិបូរណ៍ និងព្រះជន្មាយុយឺនយូរ

៦- អបអរសាទរខួបអនុស្សាវរីយ៍លើកទី ៧២ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា (៩.១១.១៩៥៣-៩.១១.២០២៥)

៧- អបអរសាទរ ខួបអនុស្សាវរីយ៍លើកទី ៧២ នៃទិវាកំណើតកងយោធពលខេមរភូមិន្ទ (៩.១១.១៩៥៣-៩.១១.២០២៥)

៨- ជយោ! ព្រះរាជាណាចក្រកម្ពុជា

៩- ជាតិ សាសនា ព្រះមហាក្សត្រ

១០- ប្តេជ្ញាការពារឯករាជ្យជាតិ បូរណភាពទឹកដី ឱ្យបានគង់វង្ស ជានិច្ចនិរន្តរ៍

១១- ជយោ! សន្តិភាព និងការអភិវឌ្ឍ

១២- មានសន្តិភាព ទើបមានការអភិវឌ្ឍប្រទេសជាតិ

១៣- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

១៤- ជយោ! សន្តិភាព ដោយនយោបាយ ឈ្នះ ឈ្នះ

១៥- ជយោ! នយោបាយ ឈ្នះ ឈ្នះ នាំមកនូវសន្តិភាព

១៦- អរគុណសន្តិភាព ក្រោមការដឹកនាំរបស់ **សម្តេចតេជោ ហ៊ុន សែន**

១៧- ជយោ! សន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍ

១៨- ជយោ! លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា